# ខ្សែភាពយន្តរឿង “ល្បែងខ្មោច” គឺជាការនិយាយលេងសើចពីអំពើប្រល័យពូជសាសន៍

ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០៦ គឺជាទិវារំឭកដល់ការសម្លាប់រង្គាលជនជាតិជ្វីហ្វ ។ ទិវានេះប្រារព្ធឡើងដើម្បីរំឭកដល់វិញ្ញាណក្ខន្ធជនជាតិជ្វីហ្វជាង៦លាននាក់ដែលបានស្លាប់ក្នុងកណ្តាប់ដៃណាហ្ស៊ីកាលពី៦០ឆ្នាំមុន ។ នៅក្នុងទិវានេះមានការរៀបពិធីបុណ្យផ្សេងៗដូចជា ការអានឈ្មោះអ្នកស្លាប់ ការអុជទៀនបំភ្លឺ ការបួងសួង ការសូត្រធម៌ និងការថ្លែងអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកដែលរស់រានមានជីវិតពីរបបហ៊ីត្លែរ ។ នេះគឺជាថ្ងៃដែលប្រជាជនជ្វីហ្វបញ្ឈប់ភាពល្ងង់ខ្លៅរបស់ខ្លួនដោយការបង្រៀនអ្នកដទៃឲ្យយល់អំពីភាពគួរឲ្យរន្ធត់នៃរបបប្រល័យពូជសាសន៍ ។

ខ្ញុំមិនសប្បាយចិត្តទាល់តែសោះដែលក្រុមអ្នកផលិតខ្សែភាពយន្តរឿង “ល្បែងខ្មោច” ត្រូវបានបង្រៀនខុស ។ ខ្សែភាពយន្តរឿង “ល្បែងខ្មោច” ចាប់ផ្តើមបញ្ចាំងពីរថ្ងៃបន្ទាប់ពីទិវារំឭកការសម្លាប់រង្គាលលើជនជាតិជ្វីហ្វ ហើយខ្សែភាពយន្តនេះផ្តើមឡើងដោយក្លែង ឈ្មោះមន្ទីរឃុំឃាំងស-២១របស់ខ្មែរក្រហម (ដែលនៅក្នុងខ្សែភាពយន្តហៅថា “ស-១១”) ។ ចំពោះអ្នកដែលស្លាប់ដោយសារខ្វះអាហារ ទារុណកម្ម និងការសម្លាប់នៅក្នុងមន្ទីរឃុំឃាំងស-២១ នេះមិនមែនជាល្បែងឡើយ ។ ក្នុងចំណោមជនរងគ្រោះជាង១ម៉ឺន៤ពាន់នាក់ក្នុងមន្ទីរឃុំឃាំងស-២១ មានតែ១២នាក់ប៉ុណ្ណោះដែលរួចផុតពីសេចក្តីស្លាប់ ។

ក្រុមអ្នកផលិតខ្សែភាពយន្តនេះបានទាញយកផលប្រយោជន៍អំពីរឿងរ៉ាវទុក្ខវេទនាមួយនេះ និងកំពុងតែប្រមាថចំពោះអ្នកស្លាប់និងសមាជិកគ្រួសារដែលកំពុងតែរស់រានមានជីវិត ។ ការប៉ះទង្គិចផ្លូវចិត្តអាចនឹងផុសឡើងវិញពេលដែលសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមចាប់ផ្តើមនៅឆ្នាំក្រោយ ។ ខ្សែភាពយន្តនេះជាការចំអកដល់អារម្មណ៍ភ័យខ្លាចរបស់ប្រជាជនកម្ពុជាស្លូតត្រង់ ។

ខ្ញុំឆ្ងល់ថា ប្រសិនបើប្រទេសថៃជាអ្នកឆ្លងកាត់អំពើប្រល័យពូជសាសន៍វិញ តើប្រទេសថៃនឹងផលិតខ្សែភាពយន្ត “ល្បែងខ្មោច” នៅក្នុងគុកនៅទីក្រុងបាងកកដែរឬទេ? តើប្រទេសថៃនឹងយករូបថតជនរងគ្រោះ ឆ្អឹងលលាដ៍ក្បាល និងវិញ្ញាណក្ខន្ធឪពុកម្តាយរបស់ខ្លួន ធ្វើជាការកម្សាន្តដែរឬទេ?

**ឆាំង យុ**